# គោលការណ៍ណែនាំនៃអង្គការសហប្រជាជាតិ
# សំរាប់បង្ការយុវទោសកម្ម ឆ្នាំ ១៩៩០

## មាតិកា


១. គោលការណ៏ណែនាំនៃអង្គការសហប្រជាជាតិសំរាប់បង្កាយុវទោសកម្ម ១៩៩០............................

I. គោលការណ៏មូលដ្ឋាន ......................................................................

II. វិសាលភាពនៃគោលការណ៏ណែនាំ..................................................................

III. ការបង្ការទូទៅ..........................................................................

IV. ដំណើរការសង្គមូបនីយកម្ម......................................................................

ក. គ្រួសារ..........................................................................

ខ. ការអប់រំ ..........................................................................

គ. សហគមន៏ ..........................................................................

ឃ. ប្រព័ន្ធផ្សព្វផ្សាយពតិមាន......................................................................

V. គោលនយោបាយសង្គម ......................................................................

VI. នីតិកម្ម និង គ្រប់គ្រងវិស័យយុត្តិធមិយុវជន.......................................................

VII. ការស្រាវជ្រាវ ការអភិវឌ្ឍន៏គោលនយោបាយ និង ការសំរបសំរួល..............................

## គោលការណ៍ណែនាំនៃអង្គការសហប្រជាជាតិ
## សំរាប់បង្ការយុវទោសកម្ម ឆ្នាំ ១៩៩០

( គោលការណ៍ណែនាំក្រុងរីយ៉ាត)

អនុម័ត និងប្រកាសដោយសេចក្តីសំរេចមហាសន្និបាតលេខ៤៥/១១២ចុះថ្ងៃទី១៤ ធ្នូ ឆ្នាំ១៩៩០

### I. គោលការណ៍មូលដ្ឋាន

១. ការបង្កាយុវទោសកម្មជាផ្នែកសំខាន់មួយនៃការបង្កាឧក្រិដ្ឋកម្មនៅក្នុងសង្គម ។ ដោយចូលរួមក្នុងសកម្មភាពស្របច្បាប់ និង មានប្រយោជន៍ដល់សង្គម និង ដោយធ្វើការតំរង់ទិសតាមសេចក្តីត្រូវការរបស់មនុស្សដើម្បីឆ្ពោះទៅរកការចូលរួមក្នុងសង្គម និង ទស្សនៈនៃជីវិតមនុស្សក្មេងៗ អាចដុះតរិយាបថមិនតំរង់ទៅរកឧក្រិដ្ឋកម្ម ។

២. ការបង្កាយុវទោសកម្មសដោយជោគជ័យត្រូវការកិច្ចប្រឹងប្រែងរបស់សង្គមទាំងមូល ដើម្បីធានាការចំរើនលូតលាស់យ៉ាងសុខដុមនៃមនុស្សជំទង់ដោយយកចិត្តទុកដាក់ និង ការលើកស្ទួយបុគ្គលិកលក្ខណៈរបស់អ្នកទាំងនោះតាំងពីកុមារវ័យមក ។

៣. ក្នុងការបកស្រាយគោលការណ៍ណែនាំបច្ចុប្បន្ននេះ គេត្រូវគិតដល់ទស្សនៈវិស័យរបស់កុមារ ។ មនុស្សក្មេងត្រូវមានតួនាទីសកម្ម និងមានចំណែកមួយនៃសង្គម និងមិនត្រូវចាត់ទុកមនុស្សក្មេងគ្រាន់តែជាមនុស្សដែលទទួលឥទ្ធិពលរបស់សង្គម ឬ គ្រាន់តែជាមនុស្សដែលចាំទទួលបញ្ជាពីគេប៉ុណ្ណោះទេ ។

៤. ស្របតាមប្រព័ន្ធច្បាប់របស់ប្រទេស សុខមាលភាពរបស់មនុស្សក្មេងចាប់ពីកុមារភាពមកជា ចំណុចផ្តោតនៃកម្មវិធីបង្កាណាមួយ ។

៥. សេចក្តីត្រូវការឱ្យមាន និងសារសំខាន់នៃគោលនយោបាយបង្កាយុវទោសកម្ម និង ការសិក្សាដោយមានបែបផែន និង ការបង្កើតវិធានការគួរត្រូវបានទទួលស្គាល់ ។ ការទាំងនេះគួរចៀសវាងការបញ្ចូលក្នុងប្រភេទព្រហ្មទណ្ឌ និង ការផ្តន្ទាទោសកុមារចំពោះអាកប្បកិរិយាដែលមិនបណ្តាលឱ្យមានការខូចខាតខ្លាំងដល់ការរីកចំរើនលូតលាស់របស់កុមារៗ ឬប៉ះពាល់ដល់អ្នកដទៃ ។ គោលនយោបាយ និង វិធានការទាំងនោះរួមមាន :

ក) ការផ្តល់ឱកាស ជាពិសេសឱកាសអប់រំ ដើម្បីបំពេញសេចក្តីត្រូវការផ្សេងៗគ្នារបស់មនុស្សក្មេង និង ដើម្បីធ្វើជាក្របខ័ណ្ឌគាំទ្រសំរាប់ការពារការលូតលាស់ផ្ទាល់ខ្លួនរបស់មនុស្សក្មេង ជាពិសេសក្មេងដែលសំដែងឱ្យឃើញថាអាចធ្លាក់នៅក្នុងសេចក្តីគ្រោះថ្នាក់ ឬអាចបង្កអន្តរាយដល់សង្គម និង ក្មេងដែលត្រូវការការថែទាំ និងការការពារពិសេស ។

ខ) ទស្សនៈ និងវិធីដោះស្រាយឯកទេសសំរាប់បង្កាទោសកម្ម ដោយឈរលើមូលដ្ឋាននៃច្បាប់នីតិវិធី ស្ថាប័នគ្រប់គ្រង ទីកន្លែង និងបណ្តាញបំពេញសេវាកម្មដែលមានគោលដៅកាត់បន្ថយ ការជំរុញទឹកចិត្ត ការចាំបាច់និងឱកាសសំរាប់ ឬលក្ខខ័ណ្ឌដែលនាំឱ្យមានការប្រព្រឹត្តបទល្មើស ។

គ) ការធ្វើអន្តរាគមន៍ជាផ្លូវការដែលត្រូវធ្វើជាបឋមដើម្បីផលប្រយោជន៍រួមរបស់មនុស្សក្មេង និង ដែលត្រូវធ្វើតាមមាត្រាត្រឹមត្រូវ និង សមធម៌ ។

ឃ) ការការពារសុខមាលភាព ការចំរើនលូតលាស់ សិទ្ធិនិងផលប្រយោជន៍របស់មនុស្សក្មេងទាំងអស់ ។

ង) ការចាត់ទុកថា អកប្បកិរិយា ឬការប្រព្រឹត្តរបស់យុវជនដែលមិនស្របនឹងបទដ្ឋាន និងតម្លៃសង្គមទាំងមូល ជាញឹកញាប់ជាផ្នែកមួយនៃដំណើរការចំរើនវ័យ និងការលូតលាស់ ហើយអាកប្បកិរិយា ឬការប្រព្រឹត្តនេះនឹងបាត់ទៅវិញដោយឯកឯងនៅពេលឆ្លងដល់ដំណាក់ការមនុស្សពេញវ័យ ។

ច) ការទទួលស្គាល់ថា តាមមតិភាគច្រើននៃអ្នកឯកទេស ការលាបឈ្មោះមនុស្សក្មេង ម្នាក់ជា "មនុស្សខុសគេខុសឯង" "ក្មេងល្មើស" ឬ "ក្មេងបំរុងនឹងខូច" ជាញឹកញាប់ជាការញាំងមួយចំណែកធ្វើឱ្យក្មេងមានអកប្បកិរិយាមួយមិនគួរឱ្យចង់បាន ។

៦. គួរបង្កើតសេវាកម្ម និងកម្មវិធីរបស់សហគមន៍សំរាប់បង្កាយុវទោសកម្ម ជាពិសេសនៅទីណាដែលមិនទាន់បង្កើតទីភ្នាក់ងារបែបនោះ ។ ទីភ្នាក់ងារផ្លូវការដែលជាឧបករណ៍សំរាប់ត្រួតត្រាសណ្តាប់ធ្នាប់របស់សង្គមគួរតែប្រើសំរាប់ជាមធ្យោបាយចុងក្រោយបង្អស់ប៉ុណ្ណោះ ។

## II. វិសាលភាពនៃគោលការណ៍ណែនាំ

៧. គោលការណ៍ណែនាំនេះ ត្រូវបកស្រាយ និងអនុវត្តនៅក្នុងក្របខ័ណ្ឌទូលំទូលាយនៃសេចក្តីថ្លែងការណ៍ជាសាកលស្តីពីសិទ្ធិមនុស្ស កតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិសេដ្ឋកិច្ចសង្គម និង វប្បធម៌ កតិការសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយសេចក្តីថ្លែងការណ៍អំពីសិទ្ធិកុមារ និង អនុសញ្ញាស្តីពីសិទ្ធិកុមារ និង នៅក្នុងបរិបទនៃវិធានជាបទដ្ឋានអប្បបរមាសំរាប់ការគ្រប់គ្រងវិស័យយុត្តិធម៌យុវជន (វិធានក្រុងប៉េកាំង) ព្រមទាំងឧបករណ៍ដទៃទៀត និងបទដ្ឋានទាក់ទងនឹងសិទ្ធិផលប្រយោជន៍ និង សុខមាលភាពរបស់កុមារ និងមនុស្សក្មេងទាំងអស់ ។

៨. គោលការណ៍ណែនាំនេះ ត្រូវអនុវត្តនៅក្នុងបរិបទនៃលក្ខខ័ណ្ឌសេដ្ឋកិច្ច សង្គមកិច្ចវប្បធម៌ ដែលមាននៅក្នុងរដ្ឋជាសមាជិកនីមួយៗ ។

## III. ការបង្ការទូទៅ

៩. គួរបង្កើតផែនការបង្ការទូលំទូលាយនៅគ្រប់ជាន់ថ្នាក់នៃរដ្ឋាភិបាល ហើយគួររួមបញ្ចូលដូចតទៅនេះ :

ក)	ការវិភាគដល់ជំរៅនូវបញ្ហា និង បញ្ជីកម្មសិធីសេវាកម្ម ទីកន្លែងសំរួលការ និងធនធានដែលមាន ។

ខ)	ការទទួលខុសត្រូវច្បាស់លាស់សំរាប់ទីភ្នាក់ងារ ស្ថាប័ន និង បុគ្គលិកមានគុណសម្បត្តិដែលពាក់ព័ន្ធក្នុងកិច្ចប្រឹងប្រែងបង្ការ ។

គ)	យន្តការសំរាប់សំរួលកិច្ចប្រឹងប្រែងបង្ការវាងទីភ្នាក់ងាររដ្ឋាភិបាល និង មិនមែនរដ្ឋាភិបាល ។

ឃ)	គោលនយោបាយកម្មវិធី និងយុទ្ធសាស្ត្រ ដែលមានមូលដ្ឋានលើការសិក្សាសញ្ញាប្រផ្នូលដែលត្រូវឃ្លាំមើលជាបន្តបន្ទាប់ និង វាយតម្លៃដោយហ្មត់ចត់នៅក្នុងអំឡុងពេលអនុវត្ត ។

ង)	វិធីសំរាប់កាត់បន្ថយដោយប្រសិទ្ធិភាពនូវឱកាសដែលអាចប្រព្រឹត្តអំពើទោសកម្ម ។

ច)	ការពាក់ព័ន្ធរបស់សហគមន៍តាមរយៈសេវាកម្ម និងកម្មវិធីមួយចំនួនធំ

ឆ)	សហប្រតិបត្តិការជិតស្និទ្ធច្រើនវិស័យរវាងរដ្ឋាភិបាលជាតិ រដ្ឋ និង មូលដ្ឋានដោយមានការចូលពាក់ព័ន្ធពីសំណាក់ប្រជាពលរដ្ឋ តំណាងផ្នែកឯកជនរបស់សហគមន៍ដែលត្រូវទទួលសេវាកម្ម និង ទីភ្នាក់ងារការងារ ទីភ្នាក់ងារថែទាំកុមារ អប់រំសុខភាព សង្គមកិច្ច ទីភ្នាក់ងារអនុវត្តច្បាប់ និង ទីភ្នាក់ងារតុលាការក្នុងការចាត់ការរួមគ្នាដើម្បីបង្កាយុវទោសកម្ម និង ឧក្រិដ្ឋកម្មរបស់យុវជន ។

ជ)	ការចូលរួមរបស់យុវជនក្នុងគោលនយោបាយដំណើរការបង្កាទោសកម្ម រួមមានការរត់រកធនធានសហគមន៍ ការជួយខ្លួនឯងរបស់យុវជន និង កម្មវិធីសងការខូចខាត និង ការជួយឧបត្ថម្ភជនរងគ្រោះ ។

ឈ)	បុគ្គលិកឯកទេសនៅគ្រប់ជាន់ថ្នាក់ ។

## IV. ដំណើរការសង្គមូបនីយកម្ម

១០. គួរផ្តោតឱ្យខ្លាំងលើគោលនយោបាយបង្កាដែលជួយសំរួលសង្គមូបនីយកម្ម និងការរួមរស់ឡើងវិញក្នុងសង្គមរបស់កុមារ និងមនុស្សក្មេងទាំងអស់ ជាពិសេសតាមរយៈគ្រួសារ សហគមន៍ក្រុមដែលមានសស្ថានភាពដូចគ្នាសាលារៀន ការហ្វឹកហ្វឺនវិជ្ជាជីវៈ និងពិភពការងារ ព្រមទាំងតាមរយៈអង្គការស្ម័គ្រចិត្ត ។ គួរផ្តល់សេចក្តីគោរពខ្ពង់ខ្ពស់ដល់ការចំរើនលូតលាស់ផ្ទាល់ខ្លួន និង ត្រឹមត្រូវរបស់កុមារ និងមនុស្សក្មេង ហើយគួរទទួលយកកុមារ និងមនុស្សក្មេងទាំងនេះជាភាគីស្មើភាពគ្នាក្នុងដំណើរការផ្សារភ្ជាប់ និងរួមរស់ឡើងវិញក្នុងសង្គម ។

**ក. គ្រួសារ**

១១. រាល់សង្គម គួរផ្ដល់អាទិភាពខ្ពស់លើសេចក្ដីត្រូវការ និងសុខភាពរបស់គ្រួសារ និង សមាជិកទាំងអស់នៃគ្រួសារ ។

១២. ដោយហេតុថា គ្រួសារជាឯកតាសំខាន់ក្រៃលែងដែលទទួលខុសត្រូវចំពោះសង្គមូបនីយកម្មបឋមរបស់កុមារ គួរមានកិច្ចប្រឹងប្រែងរបស់រដ្ឋាភិបាលនិងសង្គមដើម្បីថែរក្សាបូរណភាពនៃគ្រួសារ ដោយរាប់បញ្ចូលគ្រួសារដែលមានសាច់ញាតិរស់នៅចូលគ្នា ។ សង្គមមានការទទួលខុសត្រូវមួយដើម្បីជួយគ្រួសារ ក្នុងការផ្ដល់ការថែទាំនិងការការពារ និងក្នុងការធានាសុខមាលភាពផ្នែករាងកាយ និងសតិស្មារតីរបស់កុមារ ។ គួរផ្ដល់ការរៀបចំគ្រប់គ្រាន់ ដោយរួមបញ្ចូលការរៀបចំផ្នែកការថែទាំកុមារក្នុងពេលថ្ងៃ ដើម្បីទុកពេលឱ្យឪពុកម្ដាយធ្វើការ ។

១៣. រដ្ឋាភិបាលគួរបង្កើតគោលនយោបាយដែលនាំទៅរកការចិញ្ចឹមកុមារនៅក្នុងបរិយាកាសគ្រួសារមានស្ថេរភាពនិងស្រុះស្រួលគ្នា ។ គួរផ្ដល់សេវាកម្មចាំបាច់ដល់គ្រួសារដែលត្រូវការជំនួយក្នុងការដោះស្រាយលក្ខខ័ណ្ឌដែលមានអស្ថេរភាព ឬមានទំនាស់ ។

១៤. ក្នុងករណីដែលខ្វះខាត បរិយាកាសគ្រួសារដែលមានស្ថេរភាពស្រុះស្រួលគ្នា និង នៅពេលដែលកិច្ចប្រឹងប្រែងសហគមន៍ដើម្បីជួយឪពុកម្ដាយក្នុងរឿងនេះមិនបានជោគជ័យ ហើយក្រុមគ្រួសារដែលរស់នៅចូលគ្នាមិនអាចបំពេញតួនាទីនេះបាន គេត្រូវពិចារណាដល់ការទុកដាក់កុមារឱ្យនៅក្នុងបរិយាកាសមួយជំនួសគ្រួសារ រួមមានការធ្វើឱ្យនៅជាមួយគ្រួសារផ្សេងៗ និង ការសុំកូនយកទៅចិញ្ចឹម ។ ការដាក់កុមារឱ្យនៅក្នុងបរិយាកាសមួយជំនួសគ្រួសារនេះគួរដាក់យ៉ាងណាដែលអាចធ្វើបានឱ្យនៅក្នុងបរិយាកាសគ្រួសារណាដែលមានស្ថេរភាពនិងស្រុះស្រួលគ្នា ដោយក្នុងពេលជាមួយគ្នានោះត្រូវឱ្យកុមារមានគំនិតថាគេអាចរស់នៅជាមួយគ្រួសារថ្មីនេះបានជាអចិន្ត្រៃយ៍ ចៀសវាងបញ្ហាការយកទៅ "ផ្លុងចោល" ។

១៥. គួរផ្ដល់ការយកចិត្តទុកដាក់ជាពិសេសដល់កុមារនៃគ្រួសារដែលមានបញ្ហាដែលបង្កើតឡើង ដោយការផ្លាស់ប្ដូរឆាប់រហ័សនិងមិនទៀងទាត់ ផ្នែកសេដ្ឋកិច្ច សង្គម និងវប្បធម៌ ជាពិសេសកុមារនៃគ្រួសារ ម្ចាស់ស្រុក គ្រួសារគោចរ និងអ្នកភៀសខ្លួន ។ ដោយហេតុថា ការផ្លាស់ប្ដូរនោះ អាចធ្វើអោយខូចសមត្ថភាពផ្នែកសង្គមរបស់គ្រួសារដើម្បីថែបំប៉ន និងចិញ្ចឹមកូនតាមបែបប្រពៃណី ជាញឹកញាប់ដោយសារតួនាទី និងទំនាស់ វប្បធម៌ គេត្រូវរិះរកបង្កើតរបៀបរបបថ្មី និង មានប្រយោជន៍ដល់សង្គម សំរាប់ធ្វើសង្គមូបនីយកម្មកុមារ ។

១៦. គួរចាត់វិធានការ និងបង្កើតកម្មវិធី ដើម្បីផ្ដល់ឱកាសអោយគ្រួសារបានយល់ដឹងអំពីតួនាទី និង កាតព្វកិច្ចរបស់ឪពុកម្ដាយទាក់ទងនឹងការចំរើនលូតលាស់របស់កូន និង ការថែទាំកូនដោយលើកតំកើងទំនាក់ទំនងជាវិជ្ជមាន រវាង

ឪពុកម្តាយ និង កូន ដោយធ្វើអោយឪពុកម្តាយចាប់អារម្មណ៏ដល់បញ្ហារបស់កុមារ និង មនុស្សក្មេង និង ដោយជំរុញឪពុកម្តាយអោយចូលរួមក្នុងសកម្មភាពគ្រួសារ និងសកម្មភាពរបស់សហគមន៏ ។

១៧. រដ្ឋាភិបាលគួរចាត់វិធានការ ដើម្បីលើកតំកើងការរួមរស់ជាធ្លុងមួយ នឹងភាពសុខដុមរបស់គ្រួសារ និង ដើម្បីបង្កាក់ការបំបែកកូនពីឪពុកម្តាយ លើកលែងតែកាលៈទេសៈដែលប៉ះពាល់ដល់សុខមាលភាព និង អនាគតរបស់កូន ធ្វើមិនអោយមានវិធីណាមកជំនួសបាន ។

១៨. ជាការសំខាន់ត្រូវសង្កត់ធ្ងន់លើមុខងារសង្គមូបនីយកម្មរបស់គ្រួសារ និង ក្រុមគ្រួសារ ដែលរស់នៅចូលគ្នា ។ ជាការសំខាន់ដូចគ្នាត្រូវទទួលស្គាល់តួនាទី ការទទួលខុសត្រូវចូលរួម និងការចូលជាភាគីមួយរបស់មនុស្សក្មេងនៅក្នុងសង្គម ។

១៩. ក្នុងការធានាសិទ្ធិរបស់កុមារ ដើម្បីទទួលសង្គមូបនីយកម្មត្រឹមត្រូវ រដ្ឋាភិបាល និងទីភ្នាក់ងារដទៃទៀត គួរពឹងផ្អែកលើទីភ្នាក់ងារសង្គមកិច្ច និងទីភ្នាក់ងារច្បាប់ដែលមានស្រាប់ ប៉ុន្តែក្នុងករណីណាដែលស្ថាប័នជាប្រពៃណី និង ទំនៀមទំលាប់លែងមានប្រសិទ្ធិភាពតទៅទៀត គេក៏ត្រូវផ្តល់ និងបើកអោយមានវិធានការថ្មីដែរ ។

## ខ. ការអប់រំ

២០. រដ្ឋាភិបាលត្រូវមានកាតព្វកិច្ចធ្វើអោយក្មេងទាំងអស់បានទទួលការអប់រំសាធារណៈ ។

២១. ថែមលើសកម្មភាពហ្វឹកហ្វឺនក្នុងគ្រឹះស្ថានសិក្សា និងវិជ្ជាជីវៈ ប្រព័ន្ធអប់រំត្រូវផ្តោតការយកចិត្តទុកដាក់ដូចតទៅនេះ :

ក. ការបង្រៀនជាមូលដ្ឋាន និងបណ្តុះបណ្តាលការគោរពចំពោះអត្តសញ្ញាណ និង បែបផែនវប្បធម៌របស់កុមារផ្ទាល់ ការគោរពចំពោះតម្លៃសង្គមរបស់ប្រទេសដែលកុមារកំពុងរស់នៅ ការគោរពចំពោះអារ្យធម៌ទាំងឡាយអារ្យធម៌ផ្ទាល់របស់កុមារ និងចំពោះសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ។

ខ. ការលើកស្ទួយ និងការអភិវឌ្ឍន៍បុគ្គលិកលក្ខណៈ ទេពកោសល្យ និង សមត្ថភាព ផ្នែកសតិស្មារតី និងរាងកាយរបស់មនុស្សក្មេងអោយបានពេញទំហឹង ។

គ. ការធ្វើអោយមនុស្សក្មេងទៅជាអ្នកចូលរួមយ៉ាងសកម្ម និងមានប្រសិទ្ធិភាពនៅក្នុងដំណើរការអប់រំ គឺមិនមែនត្រឹមតែជាអ្នកដែលចាំតែដើរតាមដំណើរការការអប់រំនោះប៉ុណ្ណោះទេ ។

ឃ. ការទទួលយកសកម្មភាពដែលលើកតំកើងអោយមានអារម្មណ៏ផ្សារភ្ជាប់ និងជាសមាជិក នៃសាលារៀន និងសហគមន៏ ។

ង. ការលើកទឹកចិត្តអោយមនុស្សក្មេងយល់ និងគោរពទស្សនៈ និងមតិផ្សេងៗ ព្រមទាំងលក្ខណៈខុសគ្នាផ្នែកវប្បធម៌ និង លក្ខណៈខុសគ្នាដទៃទៀត ។

ច. ការផ្តល់ពត៌មាន និងការណែនាំទាក់ទងនឹងឱកាសសំរាប់ទទួលការបណ្តុះបណ្តាល បណ្តុលវិជ្ជាជីវៈ ឱកាសការងារ និងការអភិវឌ្ឍន៍ការងារប្រចាំជីវិត ។

ឆ. ការផ្តល់កិច្ចគាំទ្រជាវិជ្ជមានខាងស្មារតីដល់មនុស្សក្មេង និង ការចៀសវាងការធ្វើមិនត្រឹមត្រូវដែលប៉ះពាល់ដល់ផ្លូវចិត្តសាស្ត្រ ។

ជ. ការចៀសវាងវិធានការក្តៅផ្នែកវិន័យ ជាពិសេសការធ្វើទណ្ឌកម្មលើរូបរាងកាយ ។

២២. ប្រព័ន្ធអប់រំគួរប្រឹងប្រែងធ្វើការរួមគ្នាជាមួយឪពុកម្តាយ អង្គការសហគមន៍ និង ទីភ្នាក់ងារដែលយកចិត្តទុកដាក់នឹងសកម្មភាពរបស់មនុស្សក្មេង ។

២៣. មនុស្សក្មេង និងគ្រួសាររបស់គេគួរតែបានយល់ដឹងអំពីច្បាប់ និង សិទ្ធិ និង ការទទួលខុសត្រូវរបស់គេនៅចំពោះមុខច្បាប់ ព្រមទាំងប្រព័ន្ធតម្លៃសាកល រួមមានឧបករណ៍អង្គការសហប្រជាជាតិ ។

២៤. ប្រព័ន្ធអប់រំ គួរពង្រីកការថែទាំ និងការយកចិត្តទុកដាក់ពិសេសដល់មនុស្សក្មេង ដែលស្ថិតក្នុងគ្រោះថ្នាក់បណ្តាលមកពីសង្គម ។ កម្មវិធីបង្ការឯកទេស និងសម្ភារៈអប់រំ កម្មវិធីសិក្សា វិធីដោះស្រាយ និង ឧបករណ៍ គួបានបង្កើត និងប្រើប្រាស់អោយអស់ពីលទ្ធភាព ។

២៥. គួរផ្តល់ការយកចិត្តទុកដាក់ ជាពិសេសគោលនយោបាយ និងយុទ្ធសាស្ត្រទូលំទូលាយសំរាប់បង្ការការប្រើប្រាស់សុរា ថ្នាំញៀន និងសារជាតិដទៃទៀត ដោយមនុស្សក្មេង ។ គ្រូបង្រៀន និងអ្នកអាជីពផ្សេងទៀត គួរមានមធ្យោបាយ និងទទួលការហ្វឹកហ្វឺន ដើម្បីបង្កានិងចាត់ការទល់នឹងបញ្ហាទាំងនេះ ។ ពត៌មានស្តីពីករប្រើ ការសេពគ្រឿងញៀន រួមមានសុរា ត្រូវផ្សព្វផ្សាយដល់អង្គការនិស្សិត ។

២៦. សាលារៀនត្រូវមាននាទីជាមជ្ឈមណ្ឌលធនធាន និង ឯកសារយោងសំរាប់ផ្តល់សេវាកម្ម ផ្នែកពេទ្យ ផ្នែកពិគ្រោះយោបល់ និងសេវាកម្មផ្សេងៗទៀតដល់មនុស្សក្មេង ជាពិសេសអ្នកដែលមានសេចក្តីត្រូវការ ពិសេសនិងអ្នកដែលរងឈឺចាប់ដោយការប្រើប្រាស់ ការបណ្តោយខ្លួន ការធ្លាក់ខ្លួនរងគ្រោះ និងការកេងយកប្រយោជន៍ ។

២៧. តាមរយៈកម្មវិធីអប់រំផ្សេងៗគ្រូបង្រៀន និងមនុស្សពេញវ័យដទៃទៀត និងអង្គការនិស្សិតត្រូវចាប់អារម្មណ៍ដល់បញ្ហា សេចក្តីត្រូវការ និង ការយល់ឃើញរបស់មនុស្សក្មេង ជាពិសេសអ្នកដែលក្នុងចំណោមក្រុមមនុស្សទន់ខ្សោយ អ្នកបាត់បង់ប្រៀប ក្រុមជាតិពន្ធ ឬក្រុមជនជាតិភាគតិច និង ក្រុមមានចំណូលតិចដទៃទៀត ។

២៨. ប្រព័ន្ធសាលារៀនគួរព្យាយាមធ្វើអោយបានសំរេច និងលើកស្ទួយបទដ្ឋានវិជ្ជាជីវៈ និងអប់រំខ្ពស់បំផុតចំពោះកម្មវិធីសិក្សាវិធីបង្រៀន និង របៀបរៀនសូត្រ និង ការជ្រើសរើស និងហ្វឹកហ្វឺនគ្រូបង្រៀន ដែលមានគុណសម្បត្តិ ។

គួរធានាអោយមានការតាមដាន និងការវាយតម្លៃជាប្រចាំអំពីការបំពេញការងារដោយអង្គការវិជ្ជាជីវៈ និងអាជ្ញាធរសមស្រប ។

២៩. ប្រព័ន្ធសាលារៀនគួរធ្វើផែនការបណ្ដុះបណ្ដាល និង អនុវត្តសកម្មភាពក្រៅកម្មវិធីសិក្សា ដែលមានប្រយោជន៍ដល់មនុស្សក្មេង ដោយធ្វើសហប្រតិបត្តិការជាមួយក្រុមសហគមន៍ ។

៣០. គួរផ្ដល់ការជួយឧបត្ថម្ភពិសេសដល់កុមារ និងមនុស្សក្មេងដែលមានការពិបាកក្នុងការប្រតិបត្តិ តាមបទបញ្ជាវត្តមាននៅសាលារៀន និងដល់អ្នកដែល " បោះបង់សាលារៀន " ។

៣១. សាលារៀនគួរលើកស្ទួយគោលនយោបាយ និង វិធានដែលត្រឹមត្រូវ និងយុត្តិធម៌ ។ និស្សិតគួរមានតំណាងនៅក្នុងគណៈកម្មការដែលកំណត់គោលនយោបាយរបស់សាលា រួមមានគោលនយោបាយស្ដីពីវិន័យ និង នៅក្នុងធ្វើសេចក្ដីសំរេច ។

**គ. សហគមន៍**

៣២. សេវាកម្ម និងកម្មវិធីរបស់សហគមន៍ដែលឆ្លើយតបនឹងសេចកតីត្រូវការពិសេស បញ្ហាផលប្រយោជន៍ និងការខ្វល់ខ្វាយរបស់មនុស្សក្មេង និង ដែលផ្ដល់យោបល់ និងសេចក្ដីណែនាំដល់មនុស្សក្មេង និង គ្រួសាររបស់គេ គួរតែបានបង្កើតឡើង ឬ ពង្រឹងកាលណាសេវាកម្ម និងកម្មវិធីនោះមានរួចហើយ ។

៣៣. សហគមន៍គួរផ្ដល់ ឬបើមានហើយគួរពង្រឹងវិធានការគាំទ្រផ្សេងៗរបស់សហគមន៍ សំរាប់មនុស្សក្មេង រួមមាន មជ្ឈមណ្ឌលអភិវឌ្ឍន៍សហគមន៍ ទីកន្លែងលំហែពេលសំរាក និង សេវាកម្មនានាដែលឆ្លើយតបនឹងបញ្ហាពិសេសរបស់កុមារ ដែលស្ថិតក្នុងគ្រោះថ្នាក់បណ្ដាលមកពីសង្គម ។ ក្នុងការផ្ដល់វិធានការជួយទាំងនេះ គួរធានាគោរពសិទ្ធិឯកត្តជន ។

៣៤. គួរបង្កើតទីកន្លែងពិសេស ដើម្បីផ្ដល់ទីជម្រកគ្រប់គ្រាន់ដល់មនុស្សក្មេង ដែលមិនអាចរស់នៅផ្ទះបានតទៅទៀត ឬដែលមិនមានផ្ទះរស់នៅ ។

៣៥. គួរផ្ដល់សេវាកម្ម និង វិធានការជួយមួយចំនួនដើម្បីដោះស្រាយការលំបាកដែលមនុស្សក្មេងបានឆ្លងកាត់ទៅកាន់ភាពពេញវ័យ ។ សេវាកម្មបែបនោះគួររាប់បញ្ចូលកម្មវិធីពិសេសសំរាប់ក្មេងប្រព្រឹត្តថ្នាំញៀន ដែលផ្ដោតធ្ងន់លើការថែទាំ ការពិគ្រោះយោបល់ ការជួយឧបត្ថម្ភ និង កិច្ចអន្តរាគមន៍ដើម្បីព្យាបាល ។

៣៦. រដ្ឋាភិបាល និងស្ថាប័នដទៃទៀត គួរផ្ដល់កិច្ចគាំទ្រផ្នែកហិរញ្ញវត្ថុ និងកិច្ចគាំទ្រដទៃទៀតដល់អង្គការស្ម័គ្រចិត្ត ដែលផ្ដល់សេវាកម្មដល់មនុស្សក្មេង ។

៣៧. គួរបង្កើត និងពង្រឹងអង្គការយុវជននៅថ្នាក់មូលដ្ឋាន និងគួរផ្តល់អោយអង្គការទាំងនេះនូវឋានៈ ចូលរួមពេញលេញនៅក្នុងការចាត់ចែងកិច្ចការសហគមន៍ ។ អង្គការទាំងនេះគួរលើកទឹកចិត្តយុវជនអោយរៀបចំគំរោងការសមូហភាពនិងស្ម័គ្រចិត្ត ជាពិសេសសគំរោងការដែលមានគោលដៅជួយមនុស្សក្មេងដែលត្រូវការជំនួយឧបត្ថម្ភ ។

៣៨. ទីភ្នាក់ងាររដ្ឋាភិបាលគួរទទួលយកការទទួលខុសត្រូវពិសេស និងផ្តល់សេវាកម្មចាំបាច់សំរាប់ក្មេងគ្មានទីលំនៅ ឬ ក្មេងរស់តាមចិញ្ចើមថ្នល់ ។ គួរត្រៀមពត៌មានអំពីទីកន្លែងសំរួលកន្លែងស្នាក់អាស្រ័យការងារ និង ទម្រង់ព្រមទាំងប្រភពជំនួយដទៃទៀតនៅក្នុងមូលដ្ឋាន សំរាប់ផ្តល់អោយមនុស្សក្មេងបានដឹងទាន់ចិត្ត ។

៣៩. គួរបង្កើតទីកន្លែងសំរួលការកំសាន្ត ពេលសំរាក និងសេវាកម្មដែលបំរើផលប្រយោជន៍មនុស្សក្មេង ហើយគួរធ្វើយ៉ាងណាអោយពួកគេបានប្រើប្រាស់ទីកន្លែង និង ទទួលសេវាកម្មទាំងនោះយ៉ាងងាយ ។

**ឃ. ប្រព័ន្ធផ្សព្វផ្សាយពត៌មាន**

៤០. ជំរុញអោយប្រព័ន្ធផ្សព្វផ្សាយពត៌មានធានាថា មនុស្សក្មេងបានទទួលពត៌មាន និង ឯកសារពីប្រភពផ្សេងៗចំរុះគ្នារបស់ជាតិ និង អន្តរជាតិ ។

៤១. គួរលើកទឹកចិត្តអោយប្រព័ន្ធផ្សព្វផ្សាយពត៌មាន ចុះផ្សាយការរួមចំណែកជាវិជ្ជមានរបស់មនុស្សក្មេងដល់សង្គម ។

៤២. គួរលើកទឹកចិត្តអោយប្រព័ន្ធផ្សព្វផ្សាយពត៌មានផ្សព្វផ្សាយពត៌មានអំពីការសេវាកម្មទីកន្លែង សំរួល និង ឱកាសសំរាប់មនុស្សក្មេងនៅក្នុងសង្គម ។

៤៣. គួរលើកទឹកចិត្តប្រព័ន្ធផ្សព្វផ្សាយពត៌មានក្នុងបរិបទទូទៅ និងទូរទស្សន៍ ព្រមទាំងការផ្សាយតាមខ្សែភាពយន្តក្នុងបរិបទពិសេស អោយផ្សព្វផ្សាយក្នុងកំរិតអប្បបរមានូវរូបភាពអាក្រាតអំពីថ្នាំញៀន និង អំពើហឹង្សា និងលើកទឹកចិត្តអោយផ្សព្វផ្សាយអោយឃើញថា អំពើហឹង្សា និងការកេងយកប្រយោជន៍ជាការមិនល្អស ព្រមទាំងចៀសវាងការផ្សាយបន្ទាបបន្ថោក និងធ្វើអោយអាប់អោយដល់កុមារ ស្ត្រី និង ទំនាក់ទំនងរវាងមនុស្ស និងមនុស្ស និងលើកទឹកចិត្តអោយលើកតំកើងគោលការណ៍ និងតួនាទីស្មើភាពគ្នា ។

៤៤. ប្រព័ន្ធផ្សាព្វផ្សាយពត៌មាន គួរដឹងអំពីតួនាទី និងការទទួលខុសត្រូវធំធេងផ្នែកសង្គមរបស់ខ្លួន ក្នុងការបញ្ជូនពត៌មានទាក់ទងនឹងការប្រើប្រាស់ថ្នាំញៀន និងសុរារបស់យុវជន ។ ប្រព័ន្ធផ្សព្វផ្សាយពត៌មានគួរប្រើអំណាចរបស់ខ្លួនសំរាប់បង្កាការប្រើប្រាស់គ្រឿងញៀន ដោយបញ្ជូនដំណឹងអោយទៀងទាត់តាមវិធីថ្លឹងថ្លែងអោយបានល្អ ។ គួរលើកស្ទួយយុទ្ធនាការមានប្រសិទ្ធិភាពយល់ដឹងពីផលវិបាកនៃគ្រឿងញៀននៅគ្រប់ជាន់ថ្នាក់ ។

## V- គោលនយោបាយសង្គម

៤៥. ទីភ្នាក់ងាររដ្ឋាភិបាលគួរផ្តល់អាទិភាពខ្ពស់ដល់ផែនការ និងកម្មវិធីសំរាប់មនុស្សក្មេង និងគួរផ្តល់មូលនិធិគ្រប់គ្រាន់ និងធនធានដទៃទៀតសំរាប់បំពេញសេវាកម្មអោយមានប្រសិទ្ធិភាព ផ្តល់ទីកន្លែងសំរួល និងបុគ្គលិកសំរាប់

សេវាកម្មថែទាំផ្នែកពេទ្យ និងសុខភាពសតិស្មារតី ការបំប៉នចំណីអាហារ ផ្ទះសម្បែង និង សេវាកម្មដទៃទៀតដែលពាក់ព័ន្ធ រួមមានការបង្ការ និងការព្យាបាលអ្នកញៀនថ្នាំ និងសុរា ដោយធានាធនធានទាំងនោះ នឹងបានដល់ និងពិតជាផ្តល់អត្ថប្រយោជន៍ដល់មនុស្សក្មេង ។

៤៦. ការដាក់មនុស្សក្មេងអោយនៅក្នុងស្ថាប័នគ្រប់គ្រង គួរទុកជាវិធានការចុងក្រោយបង្អស់ និងគួរដាក់ក្នុងរយៈពេលតិចបំផុតដែលចាំបាច់ និងគួរចាត់ទុកឧត្តមប្រយោជន៍របស់មនុស្សក្មេងជាគោលដៅសំខាន់បំផុត ។ លក្ខណៈវិនិច្ឆ័យសំរាប់អនុញ្ញាតអោយមានការធ្វើអន្តរាគមន៍ជាផ្លូវការតាមប្រភេទនេះ គួរតែបានកំណត់ និងក៏រិតត្រឹមតែស្ថានការណ៍ដូចតទៅនេះ :

ក) ក្នុងករណីដែលកុមារ ឬ មនុស្សក្មេងបានរងគ្រោះដែលបានបង្កដោយឪពុក ម្តាយ ឬអាណាព្យាបាល ។

ខ) ក្នុងករណីកុមារ ឬ មនុស្សក្មេងត្រូវបានបំពារបំពានផ្នែកភេទ រាងកាយ ឬ សតិអារម្មណ៍ ដោយឪពុកម្តាយ ឬ អាណាព្យាបាល ។

គ) ក្នុងករណីដែលកុមារ ឬមនុស្សក្មេងមិនបានគិតគូរ បោះបង់ចោល ឬ ក្មេងយកប្រយោជន៍ដោយឪពុកម្តាយ ឬ អាណាព្យាបាល ។

ឃ) ក្នុងកណីដែលកុមារ ឬមនុស្សក្មេងត្រូវបានគំរាមកំហែងបង្កសេចក្តីគ្រោះថ្នាក់ខាងផ្លូវកាយ ឬផ្លូវចិត្ត ដោយសារអាកប្បកិរិយារបស់ឪពុកម្តាយ ឬ អាណាព្យាបាល ។

ង) ក្នុងករណីដែលគ្រោះថ្នាក់ធ្ងន់ធ្ងរខាងផ្លូវកាយ ឬផ្លូវចិត្តសាស្រ្តដល់កុមារ ឬ មនុស្សក្មេងបានសំដែងអោយឃើញតាមរយៈអាកប្បកិរិយាផ្ទាល់ខ្លួនរបស់កុមារ ឬ មនុស្សក្មេងនោះ ហើយឪពុកម្តាយ ឬ អាណាព្យាបាលយុវជនខ្លួនឯង ឬ សេវាកម្មនៃសហគមន៍ក្រៅមិនអាចឆ្លើយតបគ្រោះថ្នាក់នោះដោយមធ្យោបាយណាក្រៅពីដាក់អោយស្ថិតក្នុងការគ្រប់គ្រងស្ថាប័ន ។

៤៧. ទីភ្នាក់ងាររដ្ឋាភិបាលគួរផ្តល់អោយមនុស្សក្មេងនូវឱកាសបានបន្តការអប់រំពេញវេលា ដែលឧបត្ថម្ភជាមូលនិធិដោយរដ្ឋ ក្នុងការដែលឪពុកម្តាយ ឬ អាណាព្យាបាលមិនអាចគាំទ្រមនុស្សក្មេង និងឱកាសបានទទួលការពិសោធន៍ការងារ ។

៤៨. គួរតែធ្វើផែនការ និងបង្កើតកម្មវិធីដើម្បីបង្ការទោសកម្មដោយផ្អែកលើមូលដ្ឋាននៃលទ្ធផលស្រាវជ្រាវបែបវិទ្យាសាស្រ្តដែលគួរអោយទុកចិត្តបាន ហើយតាមដានវាយតម្លៃ និងកែតម្រូវកម្មវិធីនោះស្របទៅតាមលទ្ធផលដែលរកឃើញនោះ ។

៤៩. គួរផ្សព្វផ្សាយពត៌មានបែបវិទ្យាសាស្រ្តដល់សហគមន៍វិជ្ជាជីវៈនិងដល់សាធារណៈជនទូទៅអំពី អាកប្បកិរិយា ឬស្ថានការណ៍ដែលបញ្ជាក់អោយឃើញ ឬអាចនាំអោយកុមារធ្លាក់ខ្លួនរងគ្រោះដល់រាងកាយ និងចិត្តសាស្រ្ត ការខូចខាត និងការរំលោភ ព្រមទាំងការកេងយកប្រយោជន៍ពីមនុស្សក្មេង ។

៥០. ជាទូទៅការចូលរួមនៅក្នុងផែនការ និងកម្មវិធីគួរធ្វើដោយស្ម័គ្រចិត្ត ។ មនុស្សក្មេងខ្លួនឯងគួរចូលពាក់ព័ន្ធក្នុងការធ្វើការអភិវឌ្ឍន៍ និងការអនុវត្តន៍ផែនការ និងកម្មវិធីនោះ ។

៥១. រដ្ឋាភិបាលគួរចាប់ផ្តើម ឬបន្តរុករក អភិវឌ្ឍន៍ និង អនុវត្តគោលនយោបាយ វិធានការ និងយុទ្ធសាស្ត្រនៅខាងក្នុង និង ខាងក្រៅប្រព័ន្ធយុត្តិធម៌ផ្នែកព្រហ្មទណ្ឌ ដើម្បីបង្កាអំពើហឹង្សាក្នុងគ្រួសារ ប្រឆាំង និងប៉ះពាល់ដល់មនុស្សក្មេង និងដើម្បីធានាការប្រព្រឹត្តដោយសមរម្យចំពោះជនរងគ្រោះអំពីអំពើហឹង្សាក្នុងគ្រួសារទាំងនេះ ។

## VI- នីតិកម្ម និង ការគ្រប់គ្រងវិស័យយុត្តិធម៌យុវជន

៥២. រដ្ឋាភិបាលគួរអនុម័ត និងអនុវត្តន៍ច្បាប់ និង នីតិវិធីណាមួយដើម្បីលើកស្ទួយ និងការពារសិទ្ធិ និងសុខមាលភាពរបស់មនុស្សក្មេងទាំងអស់ ។

៥៣. គួរអនុម័ត និងអនុវត្តន៍ច្បាប់ ដែលដែលបង្កាកុំអោយមានការរងគ្រោះ ការរំលោភ ការកេងយកប្រយោជន៍ និងការប្រើកុមារ និងមនុស្សក្មេងអោយធ្វើសកម្មភាពឧក្រិដ្ឋ ។

៥៤. មិនគួរដាក់កុមារ ឬមនុស្សក្មេងអោយរងវិធានការកែប្រែ ឬទណ្ឌកម្មណាដែលបន្ទាបបន្ថោកតម្លៃរបស់គេនៅទីផ្ទះ សាលារៀន ឬ នៅស្ថាប័នដទៃទៀតឡើយ ។

៥៥. ត្រូវផ្តោតការយកចិត្តទុកដាក់បង្កើតច្បាប់ និងការអនុវត្តន៍ច្បាប់ដែលសំដៅក៏រិត និងត្រួតត្រាកុំអោយកុមារអាចរកអាវុធគ្រប់ប្រភេទមកប្រើប្រាស់បាន ។

៥៦. ដើម្បីបង្កាកុមារកុំអោយជាប់ឈ្មោះអាក្រក់ ធ្លាក់ខ្លួនរងគ្រោះ និងជាប់ទោសព្រហ្មទណ្ឌតទៅទៀត គួរអនុវត្តន៍ច្បាប់ដើម្បីធានាថា អំពើណាមួយដែលមិនត្រូវចាត់ទុកថា ជាបទល្មើស ឬ មិនត្រូវទទួលទោស បើអំពើនោះប្រព្រឹត្តដោយមនុស្សពេញវ័យ អំពើនោះក៏មិនត្រូវចាត់ទុកថា ជាបទល្មើស ហើយត្រូវដាក់ទោសដែរ បើសិនជាប្រព្រឹត្តដោយមនុស្សក្មេង ។

៥៧. គួរពិចារណាបង្កើតការិយាល័យអ្នកតំណាងពលរដ្ឋ ឬអង្គការឯករាជ្យស្រដៀងគ្នា ដែលនឹងធានាថាស្ថានភាពសិទ្ធិ និងផលប្រយោជន៍របស់មនុស្សក្មេង ត្រូវបានការពារ និងធានាអោយមានការបញ្ជូនរឿងរបស់មនុស្សក្មេងបានត្រឹមត្រូវទៅអោយសេវាកម្មដែលមាន ។ អ្នកតំណាងពលរដ្ឋ ឬ អង្គការចាត់តាំងដទៃទៀត នឹងត្រួតមើលការអនុវត្តន៍គោលការណ៍ណែនាំក្រុងរីយ៉ាត វិធានក្រុងប៉េកាំង និងវិធានសំរាប់ការពារយុវជន ដែលត្រូវបានដកហូតសេរីភាព ។ អ្នកតំណាងពលរដ្ឋ ឬអង្គការដទៃទៀត នឹងបោះពុម្ពផ្សាយរបាយការណ៍អំពីដំណើរជឿនលឿនដែលបានសំរេច និងការលំបាកដែលបានជួបប្រទះក្នុងការអនុវត្តន៍ឧបករណ៍ នៅក្នុងចន្លោះពេលទៀងទាត់ ។ សេវាកម្មគាំទ្របុព្វហេតុកុមារក៏គួរបានបង្កើតដែរ ។

៥៨. បុគ្គលិកអនុវត្តន៍ច្បាប់ និងបុគ្គលិកដទៃទៀត ដែលពាក់ព័ន្ធទាំងពីរភេទ គួរទទួលការហ្វឹកហ្វឺន ដើម្បីឆ្លើយតបសេចក្តីត្រូវការពិសេសរបស់មនុស្សក្មេង ហើយត្រូវស្គាល់ និងប្រើក្នុងក៏រិតអតិបរមា ដែលអាចធ្វើបាននូវកម្មវិធី និងលទ្ធភាពលើករឿងសុំបង្វែមនុស្សក្មេងចេញពីប្រព័ន្ធយុត្តិធម៌ ។

៥៩. គួរអនុម័តច្បាប់ និងអនុវត្តន៍ច្បាប់ដោយតឹងរឹង ដើម្បីការពារកុមារ និងក្មេងកុំអោយប្រព្រឹត្តថ្នាំញៀន និងដើម្បីការពារពីពួកជួយដូរគ្រឿងញៀន ។

## VII- ការស្រាវជ្រាវ ការអភិវឌ្ឍន៍គោលនយោបាយ និង ការសំរបសំរួល

៦០. ដោយឈរលើមូលដ្ឋានច្រើនវិស័យ និង ក្នុងវិស័យតែមួយ គួរប្រឹងប្រែងនិងគួរបង្កើតយន្តការសមស្រប ដើម្បីលើកស្ទួយអន្តរកម្ម និងការសំរបសំរួលរវាងទីភ្នាក់ងារ និងសេវាកម្មសេដ្ឋកិច្ចសង្គមអប់រំ និង សុខភាព ប្រព័ន្ធយុត្តិធម៌ យុវជន សហគមន៍ និង ទីភ្នាក់ងារអភិវឌ្ឍន៍ និងស្ថាប័នពាក់ព័ន្ធដទៃទៀត ។

៦១. ការផ្លោះប្តូរពតិមាន ការពិសោធន៍ និងជំនាញដែលបានមកតាមរយៈគំរោងការកម្មវិធី ការអនុវត្តន៍ និងគំនិតផ្តួចផ្តើមទាក់ទងនឹងឧក្រិដ្ឋកម្មយុវជន ការបង្កាទោសកម្ម និងយុត្តិធម៌យុវជន គួរត្រូវបង្កើនអោយខ្លាំងក្លា នៅលំដាប់ជាតិតំបន់ និង អន្តរជាតិ ។

៦២. កិច្ចសហប្រតិបត្តិការតំបន់ និងអន្តរជាតិ លើបញ្ហាឧក្រិដ្ឋកម្មយុវជន ការបង្កាទោះសកម្ម និងយុត្តិធម៌យុវជន ដែលពាក់ព័ន្ធនឹងអ្នកច្បាប់ អ្នកជំនាញ និង អ្នកធ្វើសេចក្តីសំរេច គួរត្រូវបានបង្កើត និង ពង្រឹងតទៅទៀត ។

៦៣. កិច្ចសហប្រតិបត្តិការបច្ចេកទេស និងវិទ្យាសាស្ត្រស្តីពីបញ្ហាអនុវត្តន៍ និងបញ្ហាទាក់ទងនឹងគោលនយោបាយ ជាពិសេសនៅក្នុងការហ្វឹកហ្វឺន គំរោងសាកល្បង និងសំរាប់បង្ហាញ និងស្តីបញ្ហាជាក់លាក់ទាក់ទងនឹងការបង្កាឧក្រិដ្ឋកម្មវ៍យុវជន និង យុវទោសកម្ម គួរត្រូវបានគាំទ្រយ៉ាងមាំទាំដោយរដ្ឋាភិបាលទាំងអស់ ប្រព័ន្ធសហប្រជាជាតិ និងអង្គការពាក់ព័ន្ធដទៃទៀត ។

៦៤. គួរលើកទឹកចិត្តអោយមានកិច្ចសហការក្នុងការធ្វើការស្រាវជ្រាវបែបវិទ្យាសាស្ត្រ ទាក់ទងនឹងរបៀបមានប្រសិទ្ធិភាព សំរាប់បង្កាឧក្រិដ្ឋកម្មយុវជន និងយុវទោសកម្ម ហើយគួរផ្សព្វផ្សាយ និងវាយតម្លៃលទ្ធផលរកឃើញអំពីការស្រាវជ្រាវនោះ ។

៦៥. អង្គការ វិទ្យាស្ថាន ទីភ្នាក់ងារ និងការិយាល័យសមស្របរបស់សហប្រជាជាតិ គួរបន្តសហការណ៍ជិតស្និទ្ធ និង សំរបសំរួលលើបញ្ហាផ្សេងៗទាក់ទងនឹងតុលាការកុមារ និង ការបង្កាឧក្រិដ្ឋកម្ម យុវជន និង យុវទោសកម្ម ។

៦៦. ដោយឈរលើមូលដ្ឋានៃគោលការណ៍ណែនាំនេះ លេខាធិការដ្ឋានសហប្រជាជាតិ រួមសហប្រតិបត្តិការជាមួយស្ថាប័នដែលមានការយកចិត្តទុកដាក់ គួរបំពេញតួនាទីសកម្មក្នុងការធ្វើការស្រាវជ្រាវ សហការណ៍វិទ្យាសាស្ត្រ

ការកំណត់លទ្ធភាពជ្រើសរើសគោលយោបាយ និងការពិនិត្យមើល និងតាមដាន ការអនុវត្តន៍គោលការណ៍ណែនាំនេះ ហើយគួរធ្វើជាប្រភពពតិមានមានដ៏ជាទីទុកចិត្តអំពីរបៀបមានប្រសិទ្ធិភាព ដើម្បីបង្កាទោសកម្ម ។